# សេចក្តីប្រកាស ព័ត៌មាន

# PRESS RELEASE

## សន្និសីទសារព័ត៌មានស្តីពី ការដាក់លិខិតរួមគ្នារបស់អង្គការសង្គមស៊ីវិល ស្នើសុំកិច្ចអន្តរាគមន៍ពី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លើសេចក្តីព្រាងច្បាប់សិទ្ធិទទួលព័ត៌មាន ទៅខុទ្ទកាល័យនាយករដ្ឋមន្ត្រី

ភ្នំពេញថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ - អង្គការសង្គមស៊ីវិលចំនួន៣៣ នឹងរៀបចំធ្វើ សន្និសីទសារព័ត៌មានមួយនៅបរិវេណខុទ្ទកាល័យនាយករដ្ឋមន្ត្រី នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ៩:០០ព្រឹក ស្តីពី ការស្នើសុំឱ្យពន្លឿនសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ។

គោលបំណងសំខាន់ នៃការដាក់លិខិត គឺដើម្បីស្នើសុំកិច្ចអន្តរាគមន៍ដ៏ខ្ពង់ខ្ពស់ពី សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ដើម្បី បញ្ចប់ដំណើរការ នៃការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពី “សិទ្ធិទទួលព័ត៌មាន” ដោយមានការ ដាក់បញ្ចូលធាតុចូលពីអង្គការសង្គមស៊ីវិល និងដាក់ជូនទៅរដ្ឋសភាដើម្បីពិភាក្សា និងអនុម័តឲ្យបានឆាប់រហ័ស ។

អង្គការសង្គមស៊ីវិល បាននិងកំពុង ចូលរួមយ៉ាងសកម្មក្នុងការធានាឱ្យសម្រេចបាន នូវកម្មវិធីកំណែទម្រង់ របស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសទៅលើការលើកកម្ពស់ “សិទ្ធិទទួលព័ត៌មាន” ដើម្បីចូលរួមការលើកកម្ពស់ សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យសម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ។

## Press Conference on the Joint Letter of Civil Society Organizations urging the Intervention of Samdech Akka Moha Sena Padei Techo Hun Sen, Prime Minister of the Kingdom of Cambodia On the draft law on access to information to the Prime Minister's Office.

Phnom Penh, June 15, 2022 - 33 civil society organizations will hold a joint press conference on submitting a letter to the Prime Minister's Office to expedite the draft law on the right to information on the morning of June 16, 2022. 9:00 am at the Prime Minister's Office.

The main purpose of the letter is to request the intervention of the Prime Minister Samdech Techo Hun Sen to complete the process of drafting the law on "access to information" by Inputs from civil society organizations are submitted to the National Assembly for discussion and approval as soon as possible.

Civil society organizations have been actively involved in ensuring the implementation of the Royal Government of Cambodia's reform program, particularly in promoting the “right to Information” to contribute to the promotion of human rights and democracy for development in all areas.

## ព័ត៌មានបន្ថែម


### 1 លោក ឡាំ សុជាតិ

នាយកប្រតិបត្តិអង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)

ទូរសព្ទលេខ៖០១២៧១៨៦១១
អ៊ីមែល៖ socheat.lam@apiinstitute.org

### 2 លោក ណុប វី

នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)

ទូរសព្ទ៖ 012 519 261
អ៊ីមែល៖ ed@camboja.net

### 3 លោក អ៊ិត សូធឿត

នាយកនៃនាយកដ្ឋានប្រព័ន្ធផ្សព្វផ្សាយ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ (CCIM)

ទូរសព្ទ៖ 012 819 545
អ៊ីមែល៖ isothoeuth@vodhotnews.com

### 4 លោកស្រី ស្រី សុធារី

នាយិកានៃអង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)

ទូរសព្ទ៖ ០១៧ ៩៩ ០៣ ៧១
អ៊ីមែល៖ director@act-kh.org


Qrcode information